CITY OF LONG BEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៩ ខែឧសភាឆ្នាំ ២០២០

ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបានចាប់អនុវត្តកម្មវិធីបើកចំហរផ្លូវថ្នល់

*ការពង្រីកចិញ្ចើមផ្លូវបណ្តោះអាសន្នត្រូវបានធ្វើឡើងដើម្បីជួយដល់អាជីវកម្មក្នុងកិច្ចខិតខំបើកដំណើរការឡើងវិញ*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ជាផ្នែកដំបូងនៃគំនិតផ្តួចផ្តើមបើកផ្លូវថ្នល់របស់ទីក្រុង "ការពង្រីកចិញ្ចើមផ្លូវបណ្តោះអាសន្ន" ត្រូវបានបង្កើតឡើងនៅតំបន់ Bixby Knolls តំបន់ Belmont Shore និងតំបន់ទីប្រជុំជន (Downtown) ដើម្បីគាំទ្រដល់អាជីវកម្មនិងភោជនីយដ្ឋាននៅក្នុងកិច្ចប្រឹងប្រែងរបស់ពួកគេក្នុងការបើកដំណើរការឡើងវិញ។ Parklets ឬការពង្រីកចិញ្ចើមផ្លូវដែលហៀរចូលទៅក្នុងចំណតរថយន្តនិងតាមដងផ្លូវនឹងផ្តល់កន្លែងសុវត្ថិភាពដល់អតិថិជនក្នុងការរីករាយខណៈពេលរង់ចាំទទួលយកអាហារឬទំនិញពីអាជីវកម្មក្នុងក្រុងនិងអាចត្រូវប្រើជាតំបន់រួមសម្រាប់បរិភោគអាហារខាងក្រៅក្រោមបទបញ្ជាសុខភាពដែលបានរំពឹងថានឹងចេញនៅថ្ងៃនេះ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "កម្មវិធីបើកផ្លូវថ្នល់របស់យើងនឹងផ្តល់នូវកន្លែងបើកចំហរដែលមានសុវត្ថិភាពសម្រាប់ឱ្យភោជនីយដ្ឋានបើកដំណើរការឡើងវិញនិងសម្រាប់ឱ្យគ្រួសាររីករាយ។ ការពង្រីកចិញ្ចើមផ្លូវបណ្តោះអាសន្ននេះធ្វើឱ្យយើងអាចផ្តល់ការគាំទ្របន្ថែមដល់អាជីវកម្មខ្នាតតូចក្នុងស្រុករបស់យើងខណៈពេលដែលផ្តល់ដល់ប្រជាជននូវកន្លែងទំនេរកាន់តែច្រើនដើម្បីអនុវត្តការរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នា។"

អ្នកដែលប្រើកន្លែងផ្លូវថ្នល់បើកចំហរនិងចិញ្ចើមផ្លូវបណ្តោះអាសន្នត្រូវតែធ្វើតាមគ្រប់ផ្នែកនៃបទបញ្ជាសុខភាពបច្ចុប្បន្នរួមទាំងការអនុវត្តការរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នានិងការពាក់របាំងមុខនៅពេលដែលនៅជិតអ្នកដទៃ។

ការពង្រីកចិញ្ចើមផ្លូវជាបណ្តោះអាសន្នគឺជាផ្នែកមួយនៃកម្មវិធីសាកល្បងដែលត្រូវបានរំពឹងថានឹងបន្ថែមទីតាំងថ្មីៗជាដំបូងហើយបន្ទាប់មកនឹងរីកទៅជាការបើកចំហរផ្លូវថ្នល់ដល់ទូលំទូលាយដែលក្រុមប្រឹក្សាក្រុងបានស្នើសុំ។ គំនិតផ្តួចផ្តើមនេះនឹងរៀបចំឡើងវិញជាបណ្តោះអាសន្ននូវទីធ្លាសាធារណៈមួយចំនួនរបស់ទីក្រុងដូចជាចិញ្ចើមផ្លូវចំណតរថយន្តតាមផ្លូវនិងចំណតរថយន្តធំៗទៅជាកន្លែងមានសុវត្ថិភាពសម្រាប់ការបរិភោគអាហារដោយរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នានិងសកម្មភាពផ្សេងទៀតដែលទាក់ទងនឹងសង្កាត់ពាណិជ្ជកម្ម។

ការពង្រីកចិញ្ចើមផ្លូវបណ្តោះអាសន្ននឹងមាននៅក្នុងតំបន់ Bixby Knolls តាមផ្លូវ Atlantic Avenue និង Burlinghall Drive ហើយនៅក្នុងតំបន់ Belmont Shore នៅតាមផ្លូវ Second Street រវាងផ្លូវ Glendora Avenue និង Pomona Ave ក៏ដូចជានៅកណ្តាលក្រុងក្នុងតំបន់ទីប្រជុំជន (Downtown) នៅតាម Pine Avenue រវាងផ្លូវលេខ ៤ (Fourth Street) និងផ្លូវលេខ ៥ (Fifth Street)។ ទីក្រុងបានធ្វើការជាមួយសមាគមអាជីវកម្មនៅក្នុងសង្កាត់ដែលរួមមានសមាគមកែលម្អនៃ Bixby Knolls សមាគមពាណិជ្ជកម្មនៃ Belmont Shore និងសម្ព័ន្ធទីក្រុងឡុងប៊ិចនៃតំបន់ទីប្រជុំជន (Downtown Long Beach Alliance) ដើម្បីកំណត់ទីតាំងដែលនឹងជួយជម្រុញផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដ៏ធំបំផុតសម្រាប់សង្កាត់នីមួយៗ។ ទីក្រុងឡុងប៊ិចគ្រោងនឹងចាប់ដៃគូជាមួយសមាគមធុរកិច្ចផ្សេងៗដើម្បីបន្ថែមការពង្រីកចិញ្ចើមផ្លូវបណ្តោះអាសន្ននៅទូទាំងទីក្រុង។

នៅក្នុងកិច្ចប្រឹងប្រែងដែលពាក់ព័ន្ធផ្លូវលំនៅដ្ឋានមួយចំនួននៅទូទាំងទីក្រុងនឹងត្រូវបិទចំពោះចរាចរណ៍និងប្រែទៅជាតំបន់មានសុវត្ថិភាពសម្រាប់ប្រជាជនរីករាយនឹងសកម្មភាពខាងក្រៅដូចជាការជិះកង់ ការជិះស្គីក្តារ ឬការលេងល្បែងលោតអន្ទាក់ដោយអនុវត្តការរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នា។ ការប្រើកៅអីអង្គុយឬការដំឡើងអ្វីផ្សេងដែលស្ថិតនៅនឹងកន្លែងនឹងមិនអនុញ្ញាតនៅតាមផ្លូវថ្នល់បើកចំហរទេ។ ព័ត៌មានបន្ថែមនឹងត្រូវផ្តល់ជូននៅពេលក្រោយនៅពេលព័ត៌មានលម្អិតត្រូវបានកំណត់។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្ត ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###